**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ......៧៣៣..........ក. ស. ភ.

ថ្ងៃពុធ ២រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមពិគ្រោះថ្លៃ ការងារសាងសង់បន្ទប់ស្នាក់នៅ ទំហំ ៧ម×១២ម ចំនួន ១ខ្នង ស្ថិតនៅស្ថានីយ៍ក្អមសំណរ

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាមេត្តាជ្រាបថា កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ លើការងារសាងសង់បន្ទប់ស្នាក់នៅ ទំហំ ៧ម×១២ម ចំនួន ១ខ្នង ស្ថិតនៅស្ថានីយ៍ក្អមសំណរ។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់ នៅអង្គភាពលទ្ធកម្ម នៃកំពង់ផែស្វយ័តភ្នំពេញដែលមានអាសយដ្ឋានអគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពីថ្ងៃទី.....២.......ខែ..កក្កដា..ឆ្នាំ២០២៦តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនងលេខ ០១០ ៤៤៤ ៦៤៣ / ០១០ ៤៤៤ ៦៣៤)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើពិគ្រោះថ្លៃនៅវេលាម៉ោង.....១៤:៣០..នាទី ថ្ងៃទី.....១៦......ខែ...កក្កដា... **ឆ្នាំ២០២៦។**

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង**..១៤:៣០.នាទី ថ្ងៃទី.....១៦.....ខែ...កក្កដា..ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃ បានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ជួន សុខេម

ទីស្នាក់ការកណ្តាល: #៦៤៩ គិតវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទ (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh